# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ  សាសនា  ព្រះមហាក្សត្រ

# គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បី
# អនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ

# លក្ខន្តិកៈ

*អនុម័តដោយមហាសន្និបាតបឋម នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩*

**The Cambodian NGO Committee on CEDAW**

**NGO-CEDAW**

# សេចក្តីផ្តើម

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រា ៤២ ស្តីពីសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ បានអនុញ្ញាតឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិបង្កើតអង្គការ សមាគមដើម្បីបានចូលរួមស្តាបនាជាតិឡើងវិញ នៅលើគ្រប់វិស័យឱ្យមានការរីកចំរើនតាមបែបប្រជាធិបតេយ្យក្នុងគោលដៅចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសិទ្ធិសេដ្ឋកិច្ច សង្គម វប្បធម៌នៅទូទាំងកម្ពុជា។ ពុំមានការអភិវឌ្ឍណាដែលរីកចំរើនដោយគ្មានស្ត្រីចូលរួមនោះទេ ដូច្នេះការកាត់បន្ថយសំដៅលុបបំបាត់ការរើសអើងគ្រប់ប្រភេទលើស្ត្រីភេទ ជាការចាំបាច់ដែលត្រូវយកចិត្តទុកដាក់ ដើម្បីស្ត្រីបានចូលរួមចំណែកអភិវឌ្ឍប្រទេសស្មើបុរស។ មូលហេតុទាំងនេះហើយដែល **គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ** ត្រូវបានបង្កើតឡើងដោយអង្គការមិនមែនរដ្ឋាភិបាលចំនួន ៩ (សូមមើលឧបសម្ព័ន្ធ ១) ក្នុងឆ្នាំ១៩៩៥ ក្នុងស្ថានភាពជាបណ្តុំអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលក្រោយមកចំនួនសមាជិករបស់គណៈកម្មាធិការនេះចេះតែកើនឡើងជាបន្តបន្ទាប់។

# ជំពូក ១
# អំពីអង្គការ

## ប្រការ ១៖ ឈ្មោះរបស់អង្គការ

អង្គការ និងសមាគមដែលជាសមាជិកទាំងអស់បានឱ្យឈ្មោះបណ្តាញអង្គការនេះថា **គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ** ហៅកាត់ថា **អិនជីអូ ស៊ី-ដប** (NGO-CEDAW) និងមាន ឈ្មោះជាភាសាអង់គ្លេស The Cambodian NGO Committee on CEDAW ។

## ប្រការ ២៖ ទីស្នាក់ការ

**គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ** មានទីស្នាក់ការនៅផ្ទះលេខ ៣៥D ផ្លូវ ៣៦៨ សង្កាត់បឹង កេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ។ ទីស្នាក់ការនេះអាចមានការផ្លាស់ប្តូរតាមតំរូវការចាំបាច់ ដោយមានការសំរេចពីគណៈកម្មាធិការអចិន្ត្រៃយ៍ ។

## ប្រការ ៣៖ និមិត្តសញ្ញា និងត្រា

និមិត្តសញ្ញារបស់ **គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ** មានរាងជារង្វង់មូលមាន

វណ្ឌ ២ ជាន់ : វណ្ឌទីមួយមាន ២ វណ្ឌ និងវណ្ឌទីពីរមាន ១ វណ្ឌ។ នៅចន្លោះវណ្ឌទាំងពីរមានអក្សរពទ្ធ័ជុំវិញថា **គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ** និងមានអក្សរកាត់ **គ.អ.ល** ខណ្ឌដោយក្បាច់ដកច័ន្ទពណ៌ខៀវចាស់ មានន័យថា : មិត្តភាពប្រកបដោយនិរន្តរភាព។ ផ្ទៃខាងក្នុងមានរូបផែនទីនៃប្រទេសកម្ពុជាពណ៌ផ្ទៃមេឃខ្ចី តំណាងឱ្យស្មារតីថា : កម្ពុជាជាប្រទេសប្រកបដោយសិទ្ធិសេរីភាព និងមិនមានការរើសអើងលើស្ត្រីភេទ។ នៅកណ្តាលផែនទីមានសៀវភៅពណ៌សតំណាងអោយ **អនុសញ្ញាស៊ី-ដវ** (CEDAW) នៅលើសៀវភៅមានរូបព្រាបពណ៌ស្វាយចាស់ និងមានរូបនិមិត្តសញ្ញាស្ត្រីនៅចំកណ្តាលព្រាប តំណាងឱ្យការលើកកំពស់សិទ្ធិសមភាពយេនឌ័ររវាងស្ត្រី និងបុរសនៅកម្ពុជា។ ខាងក្រោមរូបសៀវភៅមានអក្សរ ជាភាសាអង់គ្លេសថា : The Cambodian NGO on CEDAW និងអក្សរកាត់ថា NGO-CEDAW ។

ត្រាមានទំហំ ៣៤ មីល្លីម៉ែត្រ រាងមូល យកតាមលំនាំនិមិត្តសញ្ញា និងប្រើទឹកល័ក្ខពណ៌ខៀវ ។

# ជំពូក ២
# អំពីទស្សនៈវិស័យ បេសកកម្ម និងសកម្មភាព

## ប្រការ ៤: ទស្សនៈវិស័យ

ចង់ឃើញសង្គមកម្ពុជាមួយ ដែលរាល់ការរើសអើងលើស្ត្រីភេទត្រូវបានលុបបំបាត់ ហើយមានសមភាពរវាងបុរស និងស្ត្រីលើគ្រប់វិស័យ ។

## ប្រការ ៥: បេសកកម្ម

តស៊ូមតិដើម្បីកាត់បន្ថយការរើសអើងលើស្ត្រីភេទ និងតាមដានការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទនៅកម្ពុជា។

## ប្រការ ៦: សកម្មភាព

ដើម្បីសំរេចបេសកកម្មខ្លួនដោយជោគជ័យ **គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ** អនុវត្តសកម្មភាព ដូចតទៅ:

១. ផ្សព្វផ្សាយ **អនុសញ្ញាស៊ី – ដច** (CEDAW)

២. ឃ្លាំមើលការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការរើសអើងលើស្ត្រីភេទ

៣. ធ្វើការតស៊ូមតិ ដើម្បីអោយមានការកែប្រែច្បាប់ គោលនយោបាយនានាដែលមានការរើសអើង

៤. ធ្វើការបញ្ចុះបញ្ចូល និងគាំទ្រស្ថាប័នពាក់ព័ន្ធ លើការរៀបចំសេចក្តីព្រាងច្បាប់ថ្មី ៗ ដោយដាក់បញ្ចូលស្មារតី **អនុសញ្ញាស៊ី – ដច** (CEDAW) ឱ្យរួចជាស្រេច

៥. តស៊ូមតិសុំឱ្យមានការរៀបចំតុលាការកុមារ និងគ្រួសារ ព្រមទាំងតាមដានសកម្មភាពរបស់តុលាការនេះ

៦. ផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលឱ្យមានការផ្តល់សច្ចាប័នលើឧបករណ៍ទាំងឡាយ ដែលពាក់ព័ន្ធ **អនុសញ្ញាស៊ី – ដច** (CEDAW) និងសិទ្ធិស្ត្រី

៧. សរសេររបាយការណ៍ស្រមោលជូនគណៈកម្មាធិការ **អនុសញ្ញាស៊ី-ដ** (CEDAW) ទៅអង្គការសហប្រជាជាតិ

៨. ពង្រឹងសមត្ថភាពដល់សមាជិករបស់គណៈកម្មាធិការ **ស៊ី-ដ** (NGO-CEDAW )

៩. និងសកម្មភាពផ្សេង ៗ ទៀតដើម្បីកាត់បន្ថយការរើសអើងលើស្ត្រីភេទ ។

## ជំពូក ៣

## រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច

### ប្រការ ៧: រចនាសម្ព័ន្ធ

**គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ** មានរចនាសម្ព័ន្ធដូចតទៅ :

១. គណៈកម្មាធិការ

២. គណៈអចិន្ត្រៃយ៍

៣. ប្រធាន អនុប្រធានគណៈកម្មាធិការ

៤. អគ្គលេខាធិការដ្ឋាន

៥. អនុគណៈកម្មាធិការ

### ប្រការ ៨: គណៈកម្មាធិការ

១. **គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ** ជាសម្ព័ន្ធអង្គការ សមាគមមិនមែនរដ្ឋាភិបាល ដែលមានសកម្មភាពដើម្បីបុព្វហេតុស្ត្រី ដោយមិនបំរើឱ្យគណបក្សនយោបាយណាមួយឡើយ ។

២. គណៈកម្មាធិការនេះមានសមាជិកពីរប្រភេទៈ សមាជិកពេញសិទ្ធិ និងសមាជិកសង្កេតការណ៍ ។ ការសំរេចឱ្យចូលជាសមាជិកពេញសិទ្ធិក្តី ជាសមាជិកសង្កេតការណ៍ក្តី ជាការសំរេចចិត្តរបស់គណៈ

កម្មាធិការអចិន្ត្រៃយ៍។ ក្នុងការសំរេចទទួលយកជាសមាជិក ត្រូវផ្អែកលើឯករាជ្យភាពមិនបំរើឱ្យគណបក្សនយោបាយណា ជាអង្គការ ឬសមាគម ដែលស្របច្បាប់ និងមានសកម្មភាពបំរើអោយបុព្វហេតុស្ត្រីមិនធ្វើសកម្មភាពណាដែលជាការរើសអើងលើស្ត្រី។ សមាជិកសង្កេតការណ៍ ដែលអាចក្លាយទៅជាសមាជិកពេញសិទ្ធិទៅបាន លុះត្រាតែសមាជិកនោះចូលរួមសកម្មជាអ្នកសង្កេតការណ៍យ៉ាងតិច ៣ ខែ និងអនុមត័ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយមានសំលេង ៥0 បូក ១។

៣. គណៈកម្មាធិការនេះមានសិទ្ធិសំរេច និងអនុម័តផែនការយុទ្ធសាស្ត្រ ៤ ឆ្នាំ សំរាប់គណៈកម្មាធិការកែប្រែលក្ខន្តិកៈបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន និងសមាជិកគណៈអចិន្ត្រៃយ៍។

## ប្រការ ៩: គណៈអចិន្ត្រៃយ៍

១. គណៈអចិន្ត្រៃយ៍មានសមាជិកយ៉ាងតិច ៩ រូប ដែលជាប្រធាន/នាយក ឬអនុប្រធាន/នាយករងអង្គការ សមាគមមិនមែនរដ្ឋាភិបាលជាសមាជិករបស់គណៈកម្មាធិការ ដែលបោះឆ្នោតជ្រើសរើសដោយសន្និបាតរបស់គណៈកម្មាធិការសំរាប់អាណត្តិ ២ ឆ្នាំ។

២. ប្រធាន និងអនុប្រធានគណៈកម្មាធិការ គឺជាប្រធាន អនុប្រធានគណៈអចិន្ត្រៃយ៍។

៣. ការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន និងសមាជិកគណៈអចិន្ត្រៃយ៍ត្រូវរៀបចំដោយអគ្គលេខាធិការដ្ឋាន និងត្រូវធ្វើឡើងដោយការបោះឆ្នោតពីសមាជិកទាំងអស់តាមនីតិវិធីដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

៤. តួនាទី និងភារកិច្ចៈ គណៈអចិន្ត្រៃយ៍មានតួនាទីសំរេចគោលដៅ ផែនការសកម្មភាព ស្វះស្វែងនិងកំណត់ផែនការថវិការបស់គណៈកម្មាធិការទាំងមូល ត្រួតពិនិត្យ និងជំរុញឱ្យអគ្គលេខាធិការដ្ឋាននិងអនុគណៈកម្មាធិការនានា បំពេញតួនាទីរបស់ខ្លួនឱ្យមានប្រសិទ្ធិភាព។ គណៈអចិន្ត្រៃយ៍មានអំណាចកំណត់បទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន និងសំរេចជ្រើសរើស ឬបញ្ឈប់ការងាររបស់អគ្គលេខាធិការនៃគណៈកម្មាធិការ។ គណៈអចិន្ត្រៃយ៍ជាអ្នកសំរេចចេញសេចក្តីថ្លែងការណ៍នានា និងចេញមុខតំណាងឱ្យគណៈកម្មាធិការទាំងមូល។

៥. ការសំរេចចិត្ត : គណៈអចិន្ត្រៃយ៍ធ្វើការសំរេចចិត្តតាមសម្លេងភាគច្រើននៃសមាជិកដែលមានវត្តមានក្នុងពេលប្រជុំ តែត្រូវតែមានការគាំទ្រពីប្រធាន ឬអនុប្រធាន លើកលែងតែការសំរេចនោះមានសំលេងគាំទ្រ ២ ភាគ ៣។ ក្នុងករណីមានសម្លេងស្មើគ្នា ការសំរេចត្រូវមានការគាំទ្រពីប្រធាន ឬប្រធានស្តីទី ។

៦. កូរ៉ុមនៃការប្រជុំរបស់គណៈអចិន្ត្រៃយ៍ត្រូវមានសមាជិក ២ ភាគ ៣ និងត្រូវមានវត្តមានប្រធាន ឬ អនុប្រធានចូលរួមផង។

## ប្រការ ១០: ប្រធាន និងអនុប្រធាន

១. ប្រធាន និងអនុប្រធាន មានតួនាទីដឹកនាំការងាររបស់គណៈកម្មាធិការទាំងមូល និងធ្វើយ៉ាងណាឱ្យការអនុវត្តផែនការរបស់គណៈកម្មាធិការ និងគណៈអចិន្ត្រៃយ៍អនុវត្តទៅបានដោយប្រសិទ្ធិភាព។

២. ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានក្លាយទៅជាប្រធានស្តីទីដោយស្វ័យប្រវត្តិ។ ក្នុងករណីដែលអ្នកទាំងពីរអវត្តមាន ត្រូវមានលិខិតផ្ទេរសិទ្ធិពីប្រធាន ឬប្រធានស្តីទីអោយទៅសមាជិកគណៈអចិន្ត្រៃយ៍ណាម្នាក់។

៣. ក្នុងករណីដែលប្រធានបានលាឈប់ ឬអស់សមាជិកភាព អនុប្រធានត្រូវឡើងជាប្រធានដោយស្វ័យប្រវត្តិដើម្បីបង្គ្រប់អាណត្តិ។

៤. ក្នុងករណីដែលអនុប្រធានលាឈប់ អស់សមាជិកភាព ឬឡើងជាប្រធានគណៈកម្មាធិការ សមាជិកម្នាក់ដែលបានទទួលសម្លេងគាំទ្របន្ទាប់ ត្រូវឡើងជាអនុប្រធាន ដើម្បីបំពេញកិច្ចការជំនួស ។

៥. ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការអាចត្រូវបញ្ឈប់ដោយការសំរេចពីសន្និបាត គណៈកម្មាធិការ ដោយសម្លេង ២ ភាគ ៣ តាមការស្នើសុំយ៉ាងតិចពីសមាជិក ៣ នាក់នៃគណៈអចិន្ត្រៃយ៍ ឬសមាជិក ១ ភាគ ១០ នៃគណៈកម្មាធិការទាំងមូល។

## ប្រការ ១១: អនុគណៈកម្មាធិការ

ដើម្បីធ្វើការបំពេញបេសកកម្មរបស់ខ្លួនឱ្យមានជោគជ័យ គណៈអចិន្ត្រៃយ៍អាចបង្កើតអនុគណៈកម្មាធិការមួយចំនួនតាមការចាំបាច់។ ប្រធានអនុគណៈកម្មាធិការត្រូវតែជាសមាជិកគណៈអចិន្ត្រៃយ៍ ហើយត្រូវតែជាប្រធាន/នាយក ឬអនុប្រធាន/នាយករងរបស់អង្គការ សមាគមជាសមាជិក។ ប្រធានអនុគណៈកម្មាធិការត្រូវទទួលខុសត្រូវចំពោះប្រធានគណៈកម្មាធិការ និងគណៈកម្មាធិការទាំងមូល។

## ប្រការ ១២: ការបាត់បង់សមាជិកភាព

សមាជិកគណៈកម្មាធិការអាចត្រូវបាត់បង់សមាជិកភាពពីគណៈកម្មាធិការ កាលបើអង្គការសមាគមមិនមែនរដ្ឋាភិបាលដែលជាសមាជិកនោះ បាត់បង់ឯករាជ្យភាព ឬលែងមានសកម្មភាពពាក់ព័ន្ធ

ការលើកកំពស់ការគោរពសិទ្ធិស្ត្រី ឬលុបបំបាត់ការរើសអើងលើស្ត្រីភេទ ឬបានធ្វើសកម្មភាពណាមួយ ដែលនាំឱ្យមានការរើសអើង។ ការបាត់បង់សមាជិកភាពនឹងនាំអោយបាត់បង់តំណែងជាប្រធាន អនុប្រធានគណៈកម្មាធិការ ឬសមាជិកគណៈអចិន្ត្រៃយ៍ ។ ការសំរេចបញ្ឈប់សមាជិកភាពត្រូវធ្វើឡើង ដោយគណៈអចិន្ត្រៃយ៍ តាមនីតិវិធីដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ។

## ជំពូក ៤
## អគ្គលេខាធិការដ្ឋាន

### ប្រការ ១៣: អគ្គលេខាធិការដ្ឋាន

គណៈកម្មាធិការត្រូវមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីជួយដល់ការងាររបស់ប្រធាន អនុប្រធាន និងគណៈអចិន្ត្រៃយ៍ ។ អគ្គលេខាធិការដ្ឋាននេះត្រូវដឹកនាំដោយអគ្គលេខាធិការម្នាក់ ។

### ប្រការ ១៤: អគ្គលេខាធិការ

អគ្គលេខាធិការបំពេញការងារទៅតាមកិច្ចសន្យាការងារ ដែលធ្វើឡើងជាមួយគណៈអចិន្ត្រៃយ៍ របស់គណៈកម្មាធិការ ។ អគ្គលេខាធិការត្រូវតែមានសញ្ជាតិជាខ្មែរ មានសញ្ញាប័ត្រយ៉ាងទាបត្រឹមបរិញ្ញា ឬប្រហាក់ប្រហែល មានបទពិសោធន៍យ៉ាងតិច ៣ ឆ្នាំលើការងារគ្រប់គ្រង និងការងារស្ត្រី ។ ការជ្រើសរើសត្រូវធ្វើឡើងដោយតម្លាភាព និងដោយគណៈអចិន្ត្រៃយ៍ទាំងមូល ទៅតាមនីតិវិធីដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ដែលកំណត់ដោយគណៈអចិន្ត្រៃយ៍ ។ អគ្គលេខាធិការអាចទទួលវិន័យ ឬស្តីបន្ទោសដោយប្រធានគណៈកម្មាធិការ និងអាចត្រូវបញ្ចប់កិច្ចសន្យា បន្តកិច្ចសន្យា ឬបណ្តេញចេញដោយគណៈអចិន្ត្រៃយ៍ ។

### ប្រការ ១៥: រចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាន

ក្រៅពីអគ្គលេខាធិការ អគ្គលេខាធិការដ្ឋានអាចបង្កើតឱ្យមានការិយាល័យផ្សេងៗ ទៅតាមតម្រូវការចាំបាច់ ដោយមានការយល់ព្រមឯកភាពពីគណៈអចិន្ត្រៃយ៍ ។ ការជ្រើសរើសបុគ្គលិកត្រូវសំរេច

ដោយគណៈអចិន្ត្រៃយ៍ ។ គោលការណ៍នានាពាក់ព័ន្ធនឹងដំណើរការ និងការគ្រប់គ្រងអគ្គលេខាធិការដ្ឋាននឹងចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង ដែលអនុម័តដោយគណៈអចិន្ត្រៃយ៍ ។

## ជំពូក ៥
## មហា/សន្និបាត សន្និបាតវិសាមញ្ញ

### ប្រការ ១៦: មហាសន្និបាត

គឺជាការប្រជុំរបស់សមាជិកទាំងអស់នៃគណៈកម្មាធិការរៀងរាល់ ២ ឆ្នាំម្តង ។ ការប្រជុំនេះមានគោលដៅចំបង គឺត្រួតពិនិត្យការអនុវត្តផែនការ ៤ ឆ្នាំរបស់គណៈកម្មាធិការ និងដំណើរការនៃការ អនុវត្ត **អនុសញ្ញាស៊ីដ** (CEDAW) ។ អនុម័តផែនការយុទ្ធសាស្ត្រថ្មី និងធ្វើវិសោធនកម្មលក្ខន្តិកៈ ការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន និងសមាជិកគណៈអចិន្ត្រៃយ៍ផ្សេងទៀត អាចធ្វើឡើងក្នុងសន្និបាតនេះ កាលបើអស់អាណត្តិ ឬមាននរណាម្នាក់លាឈប់ ឬអស់សម្បទា។ អគ្គលេខាធិការដ្ឋានមានតួនាទីរៀបចំការប្រជុំនេះ ។

### ប្រការ ១៧: សន្និបាត

គឺជាការប្រជុំប្រចាំឆ្នាំរបស់សមាជិកទាំងអស់ ដើម្បីត្រួតពិនិត្យការអនុវត្តការងារប្រចាំឆ្នាំរបស់គណៈកម្មាធិការ និងការអនុវត្ត **អនុសញ្ញាស៊ីដ** ។

### ប្រការ ១៨: សន្និបាតវិសាមញ្ញ

ប្រធានគណៈកម្មាធិការ ឬគណៈអចិន្ត្រៃយ៍អាចកោះហៅសមាជិកទាំងអស់ឱ្យចូលរួមសន្និបាតវិសាមញ្ញ ដើម្បីសំរេចលើការសុំធ្វើវិសោធនកម្មលក្ខន្តិកៈ អនុម័តផែនការយុទ្ធសាស្ត្រថ្មី ឬបន្ថែម ឬ ធ្វើសេចក្តីសំរេចណាមួយដែលគណៈអចិន្ត្រៃយ៍មិនអាចសំរេចបាន ។

# ជំពូក ៦
# ប្រភពថវិកា និងការប្រើប្រាស់ថវិកា

## ប្រការ ១៩: ថវិកា

ដើម្បីធានាឱ្យមានដំណើរការរបស់ **គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ** គណៈអចិន្ត្រៃយ៍ដែលមាន អគ្គលេខាធិការដ្ឋានជាសេនាធិការ ត្រូវស្វះស្វែងរកថវិកាផ្គត់ផ្គង់ដំណើរការនេះ ។ ថវិកានេះអាចបាន មកពីប្រទេសម្ចាស់ជំនួយ អង្គការមូលនិធិ អំណោយពីបុគ្គលឯកជននានា និងប្រភពផ្សេង ៗ ទៀតដែល ឆ្លើយតបទៅនឹងទស្សនៈវិស័យរបស់ **អង្គការ ស៊ីដ** (NGO-CEDAW) ។

## ប្រការ ២០: ការប្រើប្រាស់ថវិកា

រាល់ការចំណាយ និងការប្រើប្រាស់ថវិកាត្រូវមានផែនការ និងគោលការណ៍ច្បាស់លាស់ និងត្រូវមានតម្លាភាពប្រកបដោយស្មារតីសំន្សំសំចៃ ព្រមទាំងមានផលប្រយោជន៍ចំពោះ **អង្គការ ស៊ីដ** (NGO-CEDAW) ។ ការប្រើប្រាស់ហិរញ្ញវត្ថុត្រូវផ្អែកទៅតាមគោលការណ៍នៃការប្រើប្រាស ់ហិរញ្ញវត្ថុដាច់ដោយឡែកមួយ ដោយឆ្លើយតបទៅតាមគោលការណ៍ហិរញ្ញវត្ថុសកល ។

# ជំពូក ៧
# ការដាក់វិន័យ

## ប្រការ ២១: ការដាក់វិន័យ

បុគ្គលិកដែលធ្វើការបំរើឱ្យអគ្គលេខាធិការដ្ឋានត្រូវគោរព និងទទួលការដាក់វិន័យ ឬបណ្តេញចេញ ដោយយោងទៅតាមបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈរបស់ **អង្គការ ស៊ីដ** (NGO-CEDAW) ។

## ជំពូក ៨
## អវសានបញ្ញត្តិ

### ប្រការ ២២: ការធ្វើវិសោធនកម្ម

ការធ្វើវិសោធនកម្មនៃលក្ខន្តិកៈប្រព្រឹត្តិទៅបានលុះត្រាមានសម្លេងគាំទ្រ ២ ភាគ ៣ នៃសមាជិកគណៈកម្មាធិការទាំងមូល តាមការស្នើសុំជាលាយលក្ខណ៍អក្សរពីសមាជិកគណៈអចិន្ត្រៃយ៍យ៉ាងតិច ៣ រូប ឬសមាជិក ១ ភាគ ១០ នៃ **អ៊ិនជីអូ ស៊ី-ដប** (NGO-CEDAW)។

### ប្រការ ២៣ : ការរំលាយ អ៊ិនជីអូ ស៊ី-ដប

ការរំលាយ **អ៊ិនជីអូ ស៊ី-ដប** (NGO-CEDAW) អាចធ្វើទៅបាន លុះត្រាតែមានសំឡេងយល់ព្រមពីសមាជិកយ៉ាងតិច ២ ភាគ ៣ នៅក្នុងមហាសន្និបាត/សន្និបាតវិសាមញ្ញ។ ក្រោយពីការរំលាយទ្រព្យសម្បត្តិរបស់ **អ៊ិនជីអូ ស៊ី-ដប** (NGO-CEDAW) ត្រូវធ្វើវិភាគទានទៅឱ្យអង្គការរដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាលនានា ដែលមិនមែនជាសមាជិករបស់ **អ៊ិនជីអូ ស៊ី-ដប** (NGO-CEDAW) នេះបន្ទាប់ពីទូទាត់រាល់បំណុលហើយ។ ការសំរេចធ្វើវិភាគទានត្រូវធ្វើឡើងស្របពេលនឹងការសំរេច រំលាយគណៈកម្មាធិការ ហើយអោយអគ្គលេខាធិការជាអ្នកអនុវត្ត។

## ជំពូក ៩
## អន្តរបញ្ញត្តិ

### ប្រការ ២៤:

ដោយលក្ខន្តិកៈនេះបង្កើតឡើងក្រោយពី **អ៊ិនជីអូ ស៊ី-ដប** (NGO-CEDAW) បានចាប់បដិសន្ធិរួចទៅហើយ លក្ខន្តិកៈនេះត្រូវអនុម័តដោយមហាសន្និបាតបឋម និងចុះហត្ថលេខាដោយប្រធានគណៈអចិន្ត្រៃយ៍បច្ចុប្បន្ន។

*អនុម័តដោយមហាសន្និបាតបឋម នៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩*

**ប្រធានគណៈកម្មាធិការ**

**វេជ្ជ. ពុង ឈីវកេក**

**សំគាល់ :** លក្ខន្តិកៈនេះមាន ៩ ជំពូក និង ២៤ ប្រការ

ត្រូវបានចំលងជូន :

- ក្រសួងមហាផ្ទៃ
- គ្រប់អង្គការ សមាគមជាសមាជិក
- អគ្គលេខាធិការដ្ឋាន
- ទីទុកឯកសារ

# គំនូសបំព្រួញ

## រចនាសម្ព័ន្ធគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា

## ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ

NGO-CEDAW

មហា /សន្និបាត សន្និបាតវិសាមញ្ញ

គណៈកម្មាធិការអចិន្ត្រៃយ៍

- ប្រធាន ១ រូប
- អនុប្រធាន ១ រូប
- សមាជិក ៧ រូប

អគ្គលេខាធិការដ្ឋាន

- អគ្គលេខាធិការ ១ រូប
- ហិរញ្ញិក ១ រូប

| | | | | | |
|---|---|---|---|---|---|
| អនុគណៈ កម្មាធិការ | អនុគណៈ កម្មាធិការ | អនុគណៈ កម្មាធិការ | អនុគណៈ កម្មាធិការ | អនុគណៈ កម្មាធិការ | អនុគណៈ កម្មាធិការ |